## ពត៌មានបន្ថែម :

______________________ តុលាការខោនធីសម្រាប់ក្មេង

អាសយដ្ឋានតុលាការសម្រាប់ក្មេង

______________________________________________________

______________________________________________________

______________________________________________________

លេខទូរស័ព្ទតុលាការសម្រាប់ក្មេង

______________________________________________________

លោកអ្នកអាចសុំពត៌មានបន្ថែមពីទីកន្លែងកូនលោកអ្នករស់នៅ ហើយនិងអំពីរឿងក្តីតុលាការបានពីអ្នកមើលខុសត្រូវសង្គម ឬពី ភ្នាក់ងារ វែលហ្វែរ ក្នុងតំបន់របស់កូនលោកអ្នក ។ តទៅនេះ គឺ ជាបញ្ជីរាយលេខទូរស័ព្ទសំខាន់ៗក្នុងតំបន់ :



អ្នកមើលខុសត្រូវសង្គម: ______________________________

លេខទូរស័ព្ទសំខាន់ៗផ្សេងទៀតដែលនឹងផ្តល់អោយដោយខោនធី

______________________________________________________

______________________________________________________

______________________________________________________



# __________ ខោនធី

# តុលាការសម្រាប់ក្មេង

# ពត៌មានសំរាប់មាតាបិតាក្មេង



Form Approved by the
Judicial Council of California
JV-050 CM (Cambodian) [New January 1, 1999]

សូមជូនចំពោះ មាតាបិតា ឬ អាណាព្យាបាល :



## សូមអានពត៌មាននេះ ។

### 1. តើហេតុអ្វីបានជារឿងរ៉ាវនេះមានការស៊ើបអង្កេត ?

មានសេចក្តីរាយការណ៍មួយ ឬច្រើនដងស្តីពីសុវត្ថិភាពរបស់កូនលោកអ្នក; ភ្នាក់ងារប៉ូលីស ឬ អ្នកមើលខុសត្រូវសង្គមត្រូវតែធ្វើ ការស៊ើបអង្កេតដើម្បីរកមើល បើសិនជាសុវត្ថិភាព ហើយនិងការការពារកូនរបស់លោកអ្នកតម្រូវឲ្យមន្ត្រីប៉ូលីសធ្វើអន្តរាគមន៍តាមរយៈតុលាការសំរាប់ក្មេងនោះ ។

### 2. បើសិនជាគេឯកយកកូនខ្ញុំចេញពីខ្ញុំ, ដោយហេតុអ្វី ?

កូនលោកអ្នកគេប្រហែលជាឯកយកពីលោកអ្នក ហើយយកទៅដាក់ក្នុងមន្ទីរការពារថែទាំ ពីព្រោះតែភ្នាក់ងារប៉ូលីស ឬអ្នកមើលខុសត្រូវសង្គមជឿក្នុងចិត្តថាវាជាការចាំបាច់ណាស់ដែលកូនលោកអ្នកត្រូវមានការថែទាំការពារនោះ ។

មូលហេតុខ្លះ ប្រហែលជា :

a. កូនលោកអ្នកមិនបានទទួលការមើលថែរក្សាបានត្រឹមត្រូវ ឬ ជិតដល់ :

b. មានការធ្វេសប្រហែស ឬការធ្វើបាប ឬធ្វើបាបដោយវិធីកាមគុណដល់កូន :

c. ទុកកូនឲ្យគេមើលថែរក្សាដោយមនុស្សមិនមានសមត្ថភាពផ្តល់ការមើលថែទាំបានជិតដល់ ។

### 3. បើសិនជាកូនខ្ញុំមិននៅជាមួយខ្ញុំ, តើកូនខ្ញុំនៅឯណា ?



កូនលោកអ្នកប្រហែលជាស្នាក់នៅមន្ទីរខោនធីថែទាំក្មេង ឬផ្ទះចិញ្ចឹមបីបាច់ថែរក្សាបណ្តោះអាសន្ន ។ អ្នកមើលខុសត្រូវសង្គមនឹងផ្តល់ពត៌បន្ថែម ឬផ្តល់លេខទូរស័ព្ទឲ្យមកលោកអ្នកដើម្បីទូរស័ព្ទមកសួរពីការរៀបចំដែលបានធ្វើឲ្យកូនលោកអ្នក ហើយនិងការទាក់ទងមកកូននាពេលអនាគតរបស់លោកអ្នក ។ ដើម្បីឲ្យបានយល់ច្បាស់លាស់ចូរទូរស័ព្ទមកអ្នកមើលខុសត្រូវសង្គមរបស់កូនលោកអ្នកដែលមានលេខទូរស័ព្ទនៅខាងខ្នងកូនសៀវភៅនេះនៅម៉ោងធ្វើការងារ ។

### 4. តើគេនឹងប្រគល់កូនឲ្យមកខ្ញុំវិញទេ ?

វាអាចគេប្រគល់កូននោះមកឲ្យលោកអ្នកវិញ ។ អ្នកមើលខុសត្រូវ



សង្គមដែលបានដាក់ទិសឲ្យធ្វើការស៊ើបអង្កេតសំណុំករណីនឹងធ្វើការពិនិត្យមើលពត៌មានពីលោកអ្នក, ផ្ទះសម្បែង និងកូនលោកអ្នកឡើងវិញ ហើយនិងប្រព្រឹត្តធ្វើឲ្យបានស្របតាមអ្វីដែលជាមធ្យោបាយល្អបំផុត ដើម្បីធ្វើយ៉ាងណាឲ្យកូនលោកអ្នកមានសន្តិសុខគ្រប់គ្រាន់ ។ បើសិនជាគេមិនប្រគល់កូនឲ្យលោកអ្នកវិញទេ គេប្រហែលជាដាក់កូនលោកអ្នកឲ្យនៅបណ្តោះអាសន្នជាមួយ :



a. ឪពុក ឬម្តាយស្របច្បាប់របស់កូននោះ (បើសិនជាលោកអ្នក មិនរស់នៅជាមួយគ្នាទេ);

b. ញាតិសន្តាន;

c. ផ្ទះមើលចិញ្ចឹមថែទាំក្មេង ឬផ្ទះស្នាក់នៅបណ្តោះអាសន្ន ។

### 5. ចុះញាតិសន្តាននោះយ៉ាងណាដែរ ?

ច្បាប់តម្រូវឲ្យលោកអ្នកប្រាប់អ្នកមើលខុសត្រូវសង្គមពីឈ្មោះ, អាសយដ្ឋាន,លេខទូរស័ព្ទ ហើយនិងពត៌មានអំពីឪពុក ឬម្តាយ ស្របច្បាប់របស់កូនលោកអ្នក ឬញាតិសន្តានផ្សេងៗទៀត ដែលអាចមើលថែរក្សាកូនលោកអ្នកបាន ។ អ្នកមើលខុសត្រូវសង្គមនឹង ធ្វើការទាក់ទងមកពួកគេនោះ ដើម្បីស្ទង់មើល បើគេអាចមើល ថែទាំកូនលោកអ្នកបាន ហើយនិងស្ទង់ប៉ាន់មើលផ្ទះសម្បែងនោះ មានសន្តិសុខល្អសំរាប់កូនលោកអ្នកដែរឬទេ ។ ការធ្វើរបៀបនេះ កូនលោកអ្នកប្រហែលជាគេមិនបញ្ជូនកូននោះឲ្យទៅរស់នៅជាមួយអ្នកដទៃដែល កូននិងលោកអ្នកមិនដែលស្គាល់នោះឡើយ ។

### 6. តើអ្វីកើតឡើងឥឡូវនេះ ?

បើសិនជាអ្នកមើលខុសត្រូវសង្គមជឿថាកូនលោកអ្នកពុំមានសន្តិសុខការពារគ្រប់គ្រាន់ទេ អ្នកមើលខុសត្រូវសង្គមនឹងធ្វើពាក្យដាក់ ប្តឹងទៅតុលាការសំរាប់ក្មេង ដើម្បីស្នើសុំឲ្យតុលាការប្រកាសថា កូនលោកអ្នកជាកូនរបស់តុលការ ហើយរៀបចំបែបបទបញ្ជូលើការថែទាំចិញ្ចឹមបីបាច់ថែរក្សា ហើយនិងមើលខុសត្រូវកូនលោកអ្នកនោះ ។

ក្រដាសដាក់ប្តឹងដំបូងហៅថា "ក្រដាសបណ្តឹងទាមទារ" ហើយក្រដាសនេះត្រូវតែដាក់ប្តឹងក្នុងរយៈពេលពីរថ្ងៃតុលាការ (ថ្ងៃតុលាការធ្វើការងារ) ឯកយកកូនចេញពីលោកអ្នក ឬក្នុងរយៈពេលសមរម្យបើសិនជាកូននោះរស់នៅជាមួយលោកអ្នកនៅឡើយ ។

គេនឹងប្រាប់លោកអ្នកពីខែថ្ងៃឆ្នាំ, ពេលវេលា ហើយនិងទីកន្លែងធ្វើសវនាការដំបូង ។

*ជាការសំខាន់ណាស់ដែលលោកអ្នកត្រូវចូលរួមក្នុងសវនាការនេះ ។*